*រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ ១៩៩៤*

## សេចក្តីសំរេចលេខ ១១៤ សសរ
## ស្តីពីការបង្កើត ក្រុមប្រឹក្សាអនុរក្សនៃមហាវិទ្យាល័យ
## វេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តសាស្ត្រ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-ផ្អែកតាមសំណូមពរការងារចាំបាច់ ។

### សំរេច

ប្រការ ១ : បង្កើតក្រុមប្រឹក្សាអនុរក្ស នៃមហាវិទ្យាល័យ វេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តសាស្ត្រ ដែលមានសមាសភាពដូចខាងក្រោម:

| | |
|---|---|
| ១- តំណាងក្រសួងអប់រំយុវជន និង កីឡា | ប្រធាន |
| ២- តំណាងក្រសួងសុខាភិបាល | អនុប្រធាន |
| ៣- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- តំណាងក្រសួងការពារជាតិ | សមាជិក |
| ៥- តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៦- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |

ប្រការ ២ : ក្រុមប្រឹក្សាអនុរក្ស មានភារកិច្ច :

-គ្រប់គ្រង ដឹកនាំការប្រព្រឹត្តទៅរបស់មហាវិទ្យាល័យ វេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តសាស្ត្រ ដែលពាក់ព័ន្ធទៅនឹងសកម្មភាព របស់ មហាវិទ្យាល័យ ជាអាទិ៍ ការរៀបចំផ្នែក គរុកោសល្យ ផ្នែកកម្មវិធីសិក្សា ការជ្រើសរើសសាស្ត្រាចារ្យផ្នែករដ្ឋបាល ផ្នែកហិរញ្ញវត្ថុ និង ថវិកា ។

-លើកសំណើជូនក្រសួង អាណាព្យាបាលដើម្បីសុំសេចក្តីសំរេចលើបែបបទនៃការប្រលង សមាសភាពគណៈមេប្រយោគ ការប្រលងជាប់ និង ការប្រគល់សញ្ញាប័ត្រ ។

-ត្រួតពិនិត្យរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពមហាវិទ្យាល័យ របស់ព្រឹទ្ធបុរស ។

-ចាត់វិធានការចាំបាច់ដើម្បីសំរបសំរួលដោះស្រាយរាល់បាតុភាពដែលកើតមានឡើង សំដៅលើកកំពស់គុណភាពសិក្សា និង រក្សាបាននូវសន្តាប់ធ្នាប់មហាវិទ្យាល័យ វេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តសាស្ត្រ ។

ប្រការ ៣ : សមាជិកក្រុមប្រឹក្សាអនុរក្សទាំងអស់ ត្រូវចូលរួមធ្វើការងារតាមសេចក្តីអញ្ជើញ និង ណែនាំរបស់ប្រធាន ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋានដែលមានការពាក់ព័ន្ធ ព្រមទាំងឯកឧត្តម អស់លោកដែលមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្ត សេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *